៣.ចំពោះមន្ត្រីរាជការដែលអស់តួនាទីភារកិច្ច ពីក្រសួង រដ្ឋលេខាធិការដ្ឋាន និងខេត្ត ក្រុងនោះ ត្រូវប្រគល់យានជំនិះរដ្ឋអោយមកក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដែលបានផ្តល់ជូនក្នុងពេលបំពេញភារកិច្ចគ្រប់គ្រងវិញ ទោះបីជាយាន ជំនិះនោះទិញតាមរយៈថវិការដ្ឋក្តី តាមរយៈថវិកាអង្គភាពដែលរកបានក្តី ។

៤. បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន និង ខេត្ត ក្រុង ត្រូវពង្រឹងការគ្រប់គ្រងចុះ ក្នុងបញ្ជីសារពើភ័ណ្ឌ នូវទ្រព្យសម្បត្តិរបស់រដ្ឋអោយបានត្រឹមត្រូវបំ ផុត និងបង្កើនប្រសិទ្ធភាពថែទាំទុកដាក់សំដៅបំរើមុខសញ្ញារដ្ឋតែមួយប៉ុណ្ណោះ ។

ក្រោយទទួលបានសារាចរនេះសូមព្រះអង្គម្ចាស់ ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ អស់លោក អភិបាលខេត្ត ក្រុង ត្រូវផ្សព្វផ្សាយអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ÷

ជ.រាជរដ្ឋាភិបាលកម្ពុជា

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

*********

*ភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៣*

## សារាចរលេខ ១៨ សរ

## ស្តីពីការធ្វើរបាយការណ៍របស់បណ្តាក្រសួង និងរដ្ឋលេខាធិការដ្ឋានជូនគណៈរដ្ឋមន្ត្រី

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា យោងព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា និងយោងសេចក្តីប្រកាសគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៣ ដើម្បីលើកកំពស់ការងារដឹកនាំរបស់រាជរដ្ឋាភិបាល និងក្តាប់បានសភាពការរួមព្រមទាំងធ្វើសេចក្តីរាយការណ៍ថ្វាយព្រះមហាក្សត្របានទាន់ពេលវេលា រាជរដ្ឋាភិបាលសូមណែនាំបណ្តាក្រសួង និងរដ្ឋលេខាធិការដ្ឋានដូចតទៅ :

### I. ប្រភេទនិងលក្ខណៈនៃរបាយការណ៍

បណ្តាក្រសួងនិងរដ្ឋលេខាធិការដ្ឋានត្រូវផ្តល់របាយការណ៍ជូនគណៈរដ្ឋមន្ត្រីតាមកាលកំណត់និមួយៗដូចខាងក្រោម :

## ១.របាយការណ៍ប្រចាំសប្តាហ៍

ត្រូវលើកដោយសង្ខេបអំពីវិស័យការងារជំនាញរបស់សាក្រសួងនិងរដ្ឋលេខាធិការដ្ឋាននិងធ្វើការវាយតំលៃលើចំណុចសំខាន់ៗនៃសភាពការណ៍ព្រមទាំងលើកវិធានការណ៍សំរាប់អនុវត្តបន្ត ។

## ២. របាយការណ៍ប្រចាំខែ

ត្រូវលើកអំពីសកម្មភាពការងារសំខាន់ៗរបស់ក្រសួងឬរដ្ឋលេខាធិការដ្ឋានដោយយកគោលនយោបាយរបស់រាជរដ្ឋាភិបាល ផែនការការងាររបស់ក្រសួងឬរដ្ឋលេខាធិការដ្ឋាន និងរបាយការណ៍ប្រចាំសប្តាហ៍ធ្វើជាមូលដ្ឋាន ។ ក្នុងរបាយការណ៍នេះត្រូវវិភាគសភាពការណ៍អោយបានច្បាស់លាស់ និងធ្វើការប្រៀបធៀបលទ្ធផលការងារប្រចាំខែទៅ និងផែនការរួមរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។ ទន្ទឹមនេះដែរ ត្រូវលើកអំពីទិសដៅ និងវិធានការសំរាប់ដោះស្រាយបន្តក្នុងរយៈពេលខាងមុខ ។

៣. ក្រៅពីរបាយការណ៍ប្រចាំសប្តាហ៍និងខែ ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ត្រូវធ្វើរបាយការណ៍ស្តីពីសភាពការណ៍នៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋរដ្ឋាភិបាល និងផែនការរដ្ឋប្រចាំត្រីមាសទី ១ ឆមាសទី ១, ៩ ខែ និងប្រចាំឆ្នាំ ធ្វើជូនគណៈរដ្ឋមន្ត្រីនិងចំលងជូនក្រសួងផែនការ ។

## II. ការកំណត់ពេលផ្តល់របាយការណ៍ :

## ១. របាយការណ៍ប្រចាំសប្តាហ៍

ត្រូវផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីអោយបានមុនថ្ងៃ សុក្រ រៀងរាល់សប្តាហ៍

## ២. របាយការណ៍ប្រចាំខែ

ត្រូវផ្ញើមកទីស្តីការគណៈមន្ត្រីអោយបានមុនថ្ងៃទី ២៥ រៀងរាល់ខែ ។

៣. ចំពោះរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងផែនការសេដ្ឋកិច្ចសង្គមកិច្ច របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋានប្រចាំត្រីមាសទី ១ ឆមាសទី ១ , ៩ ខែ និងប្រចាំឆ្នាំ ក្រសួងផែនការមានភារកិច្ច ធ្វើការបូកសរុបជូនគណៈរដ្ឋមន្ត្រី ។

៤. ដោយឡែកចំពោះរបាយការណ៍ស្តីពីសភាពការណ៍យោធា និងសន្តិសុខរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃនៅរក្សាតាមរបៀបដូចដែលក្រសួងធ្លាប់បានអនុវត្តកន្លងមក ។

គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋានត្រូវតែងតាំងមន្ត្រីម្នាក់អោយទទួលភារកិច្ចធ្វើរបាយការណ៍និង ធ្វើទំនាក់ទំនងជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយថ្នាក់ដឹកនាំក្តាប់បាននូវសភាពការណ៍ជាប់ជាប្រចាំ និងធានាអោយការធ្វើរបាយការណ៍អនុវត្តបានល្អ និងទាន់ពេល ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់យ៉ាងមាំថា ក្រសួងនិងរដ្ឋលេខាធិការដ្ឋាននឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារសារាចរនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

********

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៣*

## សារាចរលេខ ១៩ សរ

## រាជរដ្ឋាភិបាល

សូមទូលថ្វាយ និងជំរាប
ព្រះអង្គម្ចាស់ ឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តមលេខាធិការ
គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

**កម្មវត្ថុ :** អំពីការឈប់សំរាកការងារក្នុងឱកាសបុណ្យសិទ្ធិមនុស្ស ។

អនុលោមតាមធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីចូលរួមអបអរសាទរក្នុងឱកាសបុណ្យទិវាសិទ្ធិមនុស្ស រាជរដ្ឋាភិបាលអនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករគ្រប់ក្រសួងស្ថាប័ន រដ្ឋលេខាធិការដ្ឋាននិងខេត្តក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ឈប់សំរាកការងារនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

ទទួលបានសារាចរនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តមជ្រាប និងចាត់ចែងផ្សព្វផ្សាយ អោយទូលាយដល់អង្គភាពទាំងអស់ក្រោមឱវាទ ។

សហឧបនាយករដ្ឋមន្ត្រី

ព្រះហស្តលេខា និង ត្រា
**នរោត្តម សិរីវុឌ្ឍ**

ហត្ថលេខា
**ស ខេង**